01090134

E346/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 04 / 2015
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**Declassified to Public**
**27 June 2019**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥

សម្ងាត់ / Confidential / Confidentiel

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ (សម្ងាត់)

១. កាលពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានទទួលសំណើមួយពីមេធាវីការពារក្តី នួន ជា ដែលបានដាក់អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំកោះហៅសាក្សីបន្ថែមសម្រាប់អង្គហេតុដែលត្រូវជំនុំជម្រះវគ្គដំបូង ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ("សំណើ") (ឯកសារ E346)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ (ឯកសារ E346/1) ហើយសហព្រះរាជអាជ្ញា និង មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបដោយផ្ទាល់មាត់ កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ (ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ សេចក្តីព្រាង ទំព័រ

៦៦ ដល់ ៦៩)។ នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចទៅលើសំណើសុំនេះ។ សម្អាងហេតុពេញលេញនៃសេចក្តីសម្រេចនឹងចេញនៅពេលក្រោយ។

២. អង្គជំនុំជម្រះសាលាដំបូងសូមរំឭកថា សំណើសុំនេះរួមមានសាក្សីចំនួនប្រាំមួយប្រភេទ៖

ក. សាក្សីមួយរូបដែលអាចផ្តល់ភស្តុតាងដោះបន្ទុកអំពីការប្រព្រឹត្តិទៅលើអតីតអ្នករដ្ឋការ និងទាហានរបប លន់ នល់ នៅភូមិភាគនិរតី៖ សៅ វ៉ន។

ខ. អតីតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់ចំនួនប្រាំរូប៖ មាស សារ៉ាត់ (2-TCW-821) ហ៊ុន គឹមសេង, អ៊ូច ហាន, វង្ស សារុន និង សែត យែម។

គ. អតីតកម្មាភិបាលនៅមន្ទីរសន្តិសុខក្រាំងតាចាន់ចំនួនបីរូប៖ សាំង ស៊ឹម, តូច និង អ៊ួក។

ឃ. អតីតកម្មាភិបាលស្រុកត្រាំកក់ចំនួនពីររូប៖ សាន់ ឡូន និង ទឹម ហ៊ី (2-TCW-833)។

ង. សាក្សីពីររូបដែលអាចផ្តល់សក្ខីកម្មស្តីពីការចោទប្រកាន់លើការរៀបការដោយបង្ខំ៖ ទ្រី ទូច និង សេង អុល។

ច. សាក្សីពីររូបដែលអាចផ្តល់សក្ខីកម្មអំពីខ្សែសង្វាក់នៃការរក្សាទុកឯកសារនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ៖ ស៊ូ ភីរិន្ទ និង អ៊ីវ សារិ។

៣. **អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង សម្រេច៖**

ក. **ឯកភាព** តាមសំណើសុំស្តាប់សក្ខីកម្មសាក្សី សៅ វ៉ន។ ប៉ុន្តែ សាក្សីនេះនឹងត្រូវកំណត់កាលបរិច្ឆេទផ្តល់សក្ខីកម្មក្នុងអំឡុងពេលពិនិត្យភស្តុតាងទៅលើអង្គហេតុនៅក្នុងវគ្គទីបីដែលផ្តោតទៅលើការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ រួមទាំង អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ (ឯកសារ E315 ទំព័រ ៨)។

ខ. **ឯកភាព** តាមសំណើសុំពាក់ព័ន្ធនឹងសាក្សី វង្ស សារុន (2-TCW-986) ប៉ុន្តែ **បដិសេធ** សំណើសុំពាក់ព័ន្ធនឹងអតីតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់បួនរូបផ្សេងទៀត។

គ. **បដិសេធ** សំណើសុំពាក់ព័ន្ធអតីតកម្មាភិបាលមន្ទីរសន្តិសុខក្រាំងតាចាន់បីរូប។

ឃ. **ពន្យារពេល** សម្រេចសេចក្តីទៅលើករណីអតីតកម្មាភិបាលពីររូបនៅស្រុកត្រាំកក់ រហូតដល់បញ្ចប់សក្ខីកម្មសាក្សី 2-TCW-979 និង 2-TCW-822។

ង. **ពន្យារពេល** សម្រេចសេចក្តីលើករណី ទ្រី ទូច និង សេង អុល រហូតដល់ពេលចាប់ផ្តើមសវនាការលើប្រធានបទស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

ច. **ពន្យារពេល** សម្រេចសេចក្តីលើសំណើសុំពាក់ព័ន្ធនឹង ស៊ូ ភីរិន្ទ និង អ៊ុំ សារិ។

៤. វង្ស សារុន (2-TCW-986) នឹងត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី 2-TCW-822។

៥. សម្អាងហេតុសម្រាប់សេចក្តីសម្រេចនេះ នឹងត្រូវចេញក្នុងពេលវេលាសមស្របខាងមុខ។